# ព្រះរាជសារ
## សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
## ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
### នៅក្នុងឱកាសបុណ្យខួបលើកទី ៩៩ នៃទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ ២០០៩



បងប្អូនជនរួមជាតិទាំងអស់ជាទីស្រឡាញ់រាប់អាន និងនឹករលឹកដ៏ជ្រាលជ្រៅបំផុត

នៅក្នុងឱកាសនៃការប្រារព្ធ **ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ ២០០៩ ខួបទី៩៩** ដ៏ថ្លៃថ្លានេះ ខ្ញុំមានមនោសញ្ចេតនារំភើបរីករាយ សូមចូលរួមអបអរសាទរជាមួយបងប្អូននារីកម្ពុជា នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលរួបរួមគ្នាប្រារព្ធទិវានេះឡើង ផ្សាភ្ជាប់ទៅនឹងចលនានារីទូទាំងសកលលោក ក្រោមប្រធានបទ " **ស្ត្រីចូលរួមក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច និងការងារសង្គមជាតិ** " តាមរយៈសាររបស់ខ្ញុំនេះ ។

នៅក្នុងឱកាសដ៏មហានក្ខត្តឫក្សនេះ ខ្ញុំសូមពាំនាំព្រះរាជបណ្តាំផ្ញើសួរសុខទុក្ខ និងព្រះរាជហឫទ័យនឹករលឹកដ៏ជ្រាលជ្រៅបំផុតពី **ព្រះករុណាព្រះមហាវីរក្សត្រ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត មកជូនបងប្អូន កូនចៅ ជាពិសេសនារីទូទាំងប្រទេស ដែលរួបរួមគ្នាប្រារព្ធ **ទិវានារី ៨មីនា** ដ៏អធិកអធមនេះ ដើម្បីជំរុញឱ្យមានការគាំទ្រ ការចូលរួមរបស់ស្ត្រីក្នុងសង្គមជាតិ លើគ្រប់វិស័យ រួមទាំងការផ្តល់នូវការគោរព ការស្រឡាញ់ និងតម្លៃដល់ស្ត្រីកម្ពុជា ។

ទន្ទឹមនឹងនេះ ខ្ញុំមានសេចក្តីរីករាយ និងមានមោទនភាពក្រៃលែង ដោយបានឃើញព្រះរាជាណាចក្រកម្ពុជា បានទទួលជោគជ័យគួរជាទីកត់សំគាល់ ទាំងក្នុងប្រទេស និងនៅលើឆាកអន្តរជាតិ លើកិច្ចខិតខំប្រឹងប្រែងលើកស្ទួយស្ថានភាព សិទ្ធិ អំណាច កិត្តិយស និងកិត្តិនាមនារីកម្ពុជា តាមរយៈការផ្តល់ឱកាស និងការទទួលស្គាល់យ៉ាងពិតប្រាកដនូវសមត្ថភាពស្ត្រី ក្នុងការចូលរួមកិច្ចអភិវឌ្ឍន៍នានា និងការងារសង្គម ។ លទ្ធផលទាំងអស់នេះផ្តើមចេញពីគោលនយោបាយ និងយុទ្ធសាស្ត្រដ៏ល្អរបស់រាជរដ្ឋាភិបាល គឺយុទ្ធសាស្ត្រចតុកោណ " **ដើម្បីកំណើនការងារ សមភាព និងប្រសិទ្ធភាព** " ជំហានទី១ និងទី២ ដែលក្រសួងកិច្ចការនារី រួមសហការជាមួយស្ថាប័ននានា បានអនុវត្តយ៉ាងសកម្ម ដោយមានការឧបត្ថម្ភគាំទ្រជាថវិកា និងបច្ចេកទេស ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ។

**ទិវាអន្តរជាតិនារី ៨មីនា លើកទី៩៩ ឆ្នាំ ២០០៩** នេះ ក៏ដូចជារៀងរាល់ឆ្នាំផងដែរ បានរំលឹកឱ្យយើងចងចាំពីពលិកម្មដ៏ធំធេងជាប្រវត្តិសាស្ត្ររបស់នារីកម្ពុជាយើង និងនារីនៅទូទាំងសកលលោក ក្នុងការចូលរួមចំណែកកសាងសេដ្ឋកិច្ច និងសង្គមជាតិនៅគ្រប់សម័យកាល ។ វីរភាពនេះត្រូវតែរក្សាជាសក្ខីភាព និងគំរូសំរាប់ស្ត្រីគ្រប់ជំនាន់ និងជាបទពិសោធន៍ដ៏មានតម្លៃ ដែលយើងត្រូវតែរំលឹកឡើងវិញ និងបន្តរៀនសូត្រតាម ដើម្បីសេចក្តីសុខ សេចក្តីចំរើន រុងរឿងរបស់ស្ត្រីកម្ពុជាបច្ចុប្បន្ន និងជំនាន់ក្រោយទៀត ។

ដូចបងប្អូនកូនចៅបានជ្រាបហើយថា តាំងពីដើមរៀងរហូតមកដល់បច្ចុប្បន្ន ការលើកស្ទួយស្ថានភាពរបស់ស្ត្រីនៅព្រះរាជាណាចក្រកម្ពុជាយើង ជាពិសេសក្នុងសម័យសង្គមរាស្ត្រនិយម នៃ **ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ សម្ដេចឪ សម្ដេចតា សម្ដេចតាទួត** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ការផ្ដល់ឱកាស សិទ្ធិ អំណាចដល់ស្ត្រី បានចែងយ៉ាងច្បាស់លាស់ក្នុងរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូល និងលិខិតបទដ្ឋាននានា ក្នុងគោលដៅការពារនិងផ្ដល់ឱកាសឱ្យស្ត្រីចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍លើគ្រប់វិស័យ រួមទាំងការងារសង្គមផងដែរ ។ ខ្ញុំមានសេចក្ដីសោមនស្សរីករាយ សូមគាំទ្រទាំងស្រុងនូវប្រធានបទឆ្នាំនេះ ដែលបានបង្ហាញពីការប្ដេជ្ញាបំពេញការងារឆ្ពោះទៅធ្វើការលើកកំពស់សេដ្ឋកិច្ចស្ត្រី និងការងារសង្គម ដែលស្ត្រីបាន និងកំពុងចូលរួមចំណែកយ៉ាងសកម្ម ដែលជាកត្តាគន្លឹះផ្ដល់ឥទ្ធិពលទៅដល់ការជួយធ្វើឱ្យប្រសើរឡើង នូវស្ថានភាពជីវភាព សុខុមាលភាព ឋានៈតួនាទី ការកាត់បន្ថយនូវភាពរើសអើងគ្រប់រូបភាព អំពើហិង្សា រួមទាំងសីលធម៌សង្គម តម្លៃស្ត្រីនិងគ្រួសារខ្មែរផងដែរ ។ ក្នុងពេលបច្ចុប្បន្ននេះ ថ្វីត្បិតតែស្ត្រីបានចូលរួមយ៉ាងសកម្ម នៅក្នុងវិស័យសេដ្ឋកិច្ចជាតិ និងសង្គមកិច្ចក្តី ប៉ុន្តែភាគច្រើននៅក្នុងសេដ្ឋកិច្ចខ្នាតតូចក្រៅផ្លូវការ មិនត្រូវបានរាប់បញ្ចូលទៅក្នុងសេដ្ឋកិច្ចជាតិនៅឡើយ ដែលតម្រូវឱ្យមានការគាំទ្រ និងជំរុញការចូលរួមរបស់ស្ត្រី នៅក្នុងផ្នែកសេដ្ឋកិច្ច និងការងារសង្គមឱ្យកាន់តែខ្លាំងក្លាថែមទៀត ជាពិសេសនៅក្នុងវិស័យផ្លូវការ ។ ដូច្នេះសូមឱ្យក្រសួង និងស្ថាប័នពាក់ព័ន្ធនានា ខិតខំបង្កើនការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ស្ត្រី តាមរយៈការបង្កើនជំនាញវិជ្ជាជីវៈស្របតាមទីផ្សារការងារ បង្កើនឱកាសទទួលបាននូវធនធានសំរាប់អភិវឌ្ឍន៍សេដ្ឋកិច្ច របស់ស្ត្រី ឱ្យកាន់តែប្រសើរឡើង និងផ្ដល់តម្លៃដល់ការងារដល់ស្ត្រីចូលរួមក្នុងសង្គមផងដែរ ដើម្បីស្ត្រីនិងបុរសក្លាយទៅជាធនធានរួមប្រកបដោយសក្ដានុពលរបស់ប្រទេស រស់នៅក្នុងភាពសុខក្សេមក្សាន្តទាំងផ្លូវកាយ ផ្លូវចិត្ត និងប្រកបដោយសេចក្ដីថ្លៃថ្នូរក្នុងជីវិត ។

ឆ្លៀតក្នុងឱកាសដ៏ប្រសើរថ្លៃថ្លានេះ ខ្ញុំសូមសម្ដែងនូវការកោតសរសើរផងដែរដល់ស្ថាប័ន ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលបានរៀបចំតាក់តែងសេចក្ដីព្រាងច្បាប់ និងបានអនុម័តច្បាប់ ព្រមទាំងបានកែលំអច្បាប់ពាក់ព័ន្ធនានា ដើម្បីការពារសមាជិកគ្រួសារខ្មែរ ឱ្យរស់ប្រកបដោយសុវត្ថិភាព និងមានតម្លៃក្នុងសង្គមមួយមានយុត្តិធម៌ សីលធម៌ និងសម្បូររុងរឿង ជាពិសេសបំផុតលើការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការជាតិរបស់រាជរដ្ឋាភិបាល ដែលមានបញ្ចូលខ្លឹមសារ និងសកម្មភាពនានាឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រី-បុរសនៅគ្រប់កំរិត តាំងពីថ្នាក់ជាតិរហូតដល់ ថ្នាក់មូលដ្ឋាន ។

ក្នុងនាមខ្ញុំជាប្រធានកិត្តិយស នៃ " **ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី** " ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាអនុប្រធានកិត្តិយស នៃ **ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី** ដែលបានខិតខំយកចិត្តទុកដាក់គ្រប់បែបយ៉ាង ឱ្យនារីកម្ពុជាចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ជាតិបានល្អប្រសើរ ក្នុងភាពជាដៃគូជាមួយបុរសនៅគ្រប់លំដាប់ថ្នាក់ និងជាពិសេសបំផុតចំពោះអនុសាសន៍របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ** ដែលជំរុញឱ្យមានការបង្កើនចំនួនស្ត្រីជាមន្ត្រីរាជការ និងថ្នាក់ដឹកនាំមូលដ្ឋាន ខេត្ត ស្រុក និងក្រុង នៅទូទាំងប្រទេស ដែលមានទាំងស្ត្រីចំនួន ៣០% ជាអ្នកដឹកនាំភូមិផងដែរ ។

ខ្ញុំ សូមថ្លែងអំណរព្រះគុណ និងអរគុណដ៏ជ្រាលជ្រៅចំពោះព្រះសង្ឃ បងប្អូនជនរួមជាតិ មន្ត្រីរាជការគ្រប់ក្រសួង ស្ថាប័ន ផ្នែកឯកជន និងអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិទាំងអស់ ដែលបានខិតខំប្រឹងប្រែងជួយរួមចំណែកលើកកំពស់ស្ថានភាពនារីកម្ពុជា ឱ្យឈានទៅប្រសើរឡើងជាបន្តបន្ទាប់។ ខ្ញុំមានសេចក្តីសង្ឃឹមថា កិច្ចខិតខំប្រឹងប្រែងនេះនឹងមានបន្តទៅទៀតជារៀងរហូត។

ខ្ញុំសូមកោតសរសើរ និងគាំទ្រនូវរាល់សកម្មភាពដែលក្រសួងកិច្ចការនារី បានអនុវត្តកន្លងមកប្រកបដោយលទ្ធផលជាផ្លែផ្កា និងជាបន្តបន្ទាប់ទៅទៀត ក្នុងគោលដៅលើកស្ទួយស្ត្រី-បុរសលើគ្រប់ផ្នែក និងគ្រប់វិស័យ។

ខ្ញុំសូមឧទ្ទិស **ថ្ងៃ ៨មីនា ឆ្នាំ ២០០៩** នាំមកនូវសុខសន្តិភាព ភាពរុងរឿង និងសុខុដុមរម្យនាក្នុងសង្គមមួយដែលមានសីលធម៌ខ្ពស់ ប្រាសចាកនូវរាល់ទំរង់នៃការរើសអើងគ្រប់ប្រភេទ ដើម្បីឱ្យស្ត្រី និងបុរសមានលទ្ធភាព និងឱកាសសហការគ្នាលើគ្រប់សកម្មភាពសង្គម ពីព្រោះស្ត្រីជាដៃគូដែលពុំអាចខ្វះបានជាមួយបុរសក្នុងកំណើនការងារអភិវឌ្ឍន៍សង្គម។

ក្នុងព្រះបរមនាមដ៏ខ្ពង់ខ្ពស់ នៃ **ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមគាំទ្រនូវរាល់សកម្មភាពរបស់ស្ថាប័នរដ្ឋ អង្គការក្រៅរដ្ឋាភិបាលនានា និងបងប្អូន កូនចៅទាំងអស់ ដែលបានផ្តល់ឱកាសឱ្យស្ត្រី-បុរស និងកុមារី-កុមារាខ្មែរ ទទួលបាននូវការគោរពសិទ្ធិ និងតម្លៃរបស់ខ្លួន។

ខ្ញុំសូមប្រសិទ្ធពរជ័យ សិរីមង្គលមហាប្រសើរចំពោះថ្នាក់ដឹកនាំព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល មន្ត្រីរាជការទាំងអស់ នៅគ្រប់ក្រសួង-ស្ថាប័ន មន្ទីររាជធានី ខេត្ត-ស្រុក-ក្រុង និងបងប្អូននារី ទូទាំងព្រះរាជាណាចក្រកម្ពុជា និងនារីទូទាំងសកលលោក អង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ ព្រមទាំងបងប្អូនជនរួមជាតិទាំងអស់ សូមប្រកបតែនឹងសេចក្តីសុខ សេចក្តីចំរើន គ្រប់ប្រការកុំបីឃ្លៀងឃ្លាតឡើយ៕

សូមអរគុណ

